អង្គការសហការ
INTERNATIONAL COOPERATION CAMBODIA

# អង្គការអាយស៊ីស៊ី
# គោលនយោបាយ ស្តីពីការការពារពីការកេងប្រវ័ញ្ច ការរំលោភបំពាន និងការបៀតបៀនផ្លូវភេទ (កករបផ)

## ១. ប្រវត្តិឯកសារ

| អ្នកនិពន្ធ | កាលបរិច្ឆេទ | មូលហេតុនៃការផ្លាស់ប្តូរ | ជំនាន់ | លក្ខណៈ |
|---|---|---|---|---|
| លោក សាន ប៊ុនធឿន និង លោក គិត សំណាង | ឧសភា ២០១៨ | ការតាក់តែងឯកសារ | ០.១ | ពង្រាង |
| ក្រុមនាយកប្រតិបត្តិ | ឧសភា ២០១៨ | បញ្ចូល / មតិ | | ពង្រាង |
| លោក សាន ប៊ុនធឿន និង លោក គិត សំណាង | ឧសភា ២០១៨ | កែសម្រួល | ០.២ | ពង្រាង |
| ក្រុមនាយកប្រតិបត្តិ | ៣០ ឧសភា ២០១៨ | កែសម្រួល និងអនុម័ត | ១.០ | អនុម័ត |
| លោកស្រី អៀង ហ្គេចលី និង លោក គិត សំណាង | ឧសភា - វិច្ឆិកា ២០២០ | កែសម្រួល និងធ្វើបច្ចុប្បន្នភាពដោយយោងលើធាតុចូល/អនុសាសន៍ពីបុគ្គលិក និងភាគីពាក់ព័ន្ធ | ១.១ | ពង្រាង |
| ប្រធានគម្រោង | មករា/មីនា ២០២១ | ពិគ្រោះយោបល់ជាមួយប្រធានគម្រោង តាមរយៈអនឡាញ - យោបល់និងធាតុចូលលើគោលនយោបាយ និងឧបសម្ព័ន្ធ | ១.២ | ពង្រាង |
| ក្រុមនាយកប្រតិបត្តិ | ៥ ឧសភា ២០២១ | ត្រួតពិនិត្យឡើងវិញ និងអនុម័ត | ២.០ | បញ្ចប់ |

## ២. សេចក្តីផ្តើម និង សេចក្តីថ្លែងការណ៍គោលនយោបាយ

នៅក្នុងវិស័យអភិវឌ្ឍន៍និងមនុស្សធម៌ តម្រូវការសម្រាប់ការការពារ ទាំងមនុស្សពេញវ័យងាយរងគ្រោះនិងកុមារកំពុងកើនឡើងដោយសារតែការកេងប្រវ័ញ្ច ការរំលោភបំពាន និងការបៀតបៀន។ អង្គការអាយស៊ីស៊ីនិងស្ថាប័នដៃគូ ទទួលស្គាល់ពីតម្រូវការនេះ ហើយមានបំណងការពារមនុស្សពេញវ័យងាយរងគ្រោះនិងកុមារនៅក្នុងអាណត្តិនិងសមត្ថភាពរបស់ខ្លួន។

អង្គការអាយស៊ីស៊ីផ្តោតលើអ្នកដែលត្រូវបានគេយកចិត្តទុកដាក់តិចតួច ជាពិសេសអ្នកដែលងាយរងគ្រោះបំផុតនិងបាត់បង់ឱកាសក្នុងបរិបទអភិវឌ្ឍន៍ និងបរិបទគ្រោះមហន្តរាយ។ យើងទទួលស្គាល់ថា មានភាពខុសគ្នានៃអំណាច និងភាពងាយរងគ្រោះជាបន្តបន្ទាប់នៅក្នុងសហគមន៍ ដែលយើងបម្រើដែលបង្កើនហានិភ័យនៃការកេងប្រវ័ញ្ច ការរំលោភបំពាន និងការបៀតបៀន។

អាយស៊ីស៊ីជាអង្គការគ្រីស្ទបរិស័ទជឿថា មនុស្សទាំងអស់ត្រូវបានបង្កើតមកជាតំណាងរបស់ព្រះជាម្ចាស់ ហើយមានតម្លៃស្មើៗគ្នា។ មនុស្សគ្រប់រូបគួរត្រូវបានការគោរព និងមានសិទ្ធិស្មើគ្នាក្នុងការទទួលបានការប្រព្រឹត្តចំពោះខ្លួនដោយសេចក្តីថ្លៃថ្នូរ។ នៅអង្គការអាយស៊ីស៊ី ក៏ជឿជាក់ផងដែរថាមនុស្សទាំងអស់មានសិទ្ធិរស់រានមានជីវិតដោយគ្មានអំពើហិង្សាផ្លូវភេទ និងគ្មានការរំលោភបំពានអំណាចណាមួយ ដោយមិនគិតពីអាយុ យេនឌ័រ ភេទ ទំនោរផ្លូវភេទ ពិការភាព សាសនា ឬជនជាតិដើម។

អង្គការអាយស៊ីស៊ីប្តេជ្ញាការពារពីរាល់ទម្រង់នៃការកេងប្រវ័ញ្ច ការរំលោភបំពាន និងការបៀតបៀនផ្លូវភេទ។ អង្គការអាយស៊ីស៊ីប្តេជ្ញាចិត្ត ប្រកាន់ខ្ជាប់នូវអាកប្បកិរិយាមិនរើសអើងនិងដោយគោរព ហើយមិនអាចទទួលយកបានទេនូវរាល់ទម្រង់នៃការប្រព្រឹត្តមិនត្រឹមត្រូវ។

អង្គការអាយស៊ីស៊ីប្រកាន់ជំហរមិនលើកលែងចំពោះការកេងប្រវ័ញ្ច និងការរំលោភបំពានលើមនុស្សពេញវ័យ និងកុមារ[1]ដែលចូលរួមក្នុងការងាររបស់អង្គការអាយស៊ីស៊ី។ ទោះបីគោលនយោបាយនេះអនុវត្តចំពោះមនុស្សពេញវ័យទាំងអស់ក៏ដោយ វាមានគោលបំណងឆ្លុះបញ្ចាំង ជាពិសេស ការប្តេជ្ញាចិត្តរបស់អង្គការអាយស៊ីស៊ីក្នុងការការពារបុគ្គលងាយរងគ្រោះ។ វាគឺជាការទទួលខុសត្រូវរបស់យើង ក្នុងការធានាថាមនុស្សពេញវ័យ មិនត្រូវបានដាក់នៅក្នុងស្ថានភាពដែលធ្វើឱ្យពួកគេងាយទទួលរងពីការកេងប្រវ័ញ្ច ការរំលោភបំពាន និងការបៀតបៀនផ្លូវភេទ(**ករបផ**)ដោយបុគ្គលិកអាយស៊ីស៊ី ឬអ្នកពាក់ព័ន្ធអាយស៊ីស៊ី ទោះបីជាចេតនាក្តីឬអចេតនាក្តី។

## ២.១. គោលបំណងនៃគោលនយោបាយ

គោលនយោបាយនេះ ដាក់ចេញនូវវិធីសាស្ត្ររបស់អង្គការអាយស៊ីស៊ី ដើម្បីការពារនិងដោះស្រាយការកេងប្រវ័ញ្ច ការរំលោភបំពាន និងការបៀតបៀនផ្លូវភេទ ហើយដើម្បីធានាឱ្យមានការយកចិត្តទុកដាក់ និងការឆ្លើយតបសមស្រប ប្រសិនបើការកេងប្រវ័ញ្ច ការរំលោភបំពាន ឬការបៀតបៀនផ្លូវភេទកើតឡើង។ គោលនយោបាយនេះ ពិពណ៌នាអំពីការរំពឹងទុកយ៉ាងច្បាស់នៃអាកប្បកិរិយានិងការអនុវត្តល្អ នៅពេលមានទំនាក់ទំនងជាមួយមនុស្សពេញវ័យងាយរងគ្រោះ ឬអ្នកបាត់បង់ឱកាស។

## ២.២. វិសាលភាព

គោលនយោបាយ **កករបផ** អនុវត្តចំពោះអ្នកដែលធ្វើការ ឬពាក់ព័ន្ធជាមួយអង្គការអាយស៊ីស៊ី និងការងាររបស់ខ្លួន។ គោលនយោបាយនេះ គ្របដណ្តប់បុគ្គលិកគ្រប់កម្រិត/អ្នកពាក់ព័ន្ធទាំងអស់របស់អង្គការអាយស៊ីស៊ី ទាំងក្នុងអំឡុងពេល និងក្រៅម៉ោងធ្វើការធម្មតា។

[1] អង្គការអាយស៊ីស៊ីមានគោលនយោបាយស្តីពីការការពារកុមារ និងនីតិវិធីការពារកុមារដែលមានជាធរមាន ដែលពាក់ព័ន្ធនឹងបញ្ហាទាំងឡាយណាទាក់ទិននឹងកុមារ។ គោលនយោបាយស្តីពីការការពារកុមារ អាយស៊ីស៊ី ជាប់ពាក់ព័ន្ធគ្នានឹងគោលនយោបាយស្តីពី កករបផ យ៉ាងជិតស្និត។

បុគ្គលិកអាយស៊ីស៊ី រួមមាន៖
- សមាជិកបុគ្គលិកជាតិ
- សមាជិកបុគ្គលិកបរទេស

អ្នកពាក់ព័ន្ធអាយស៊ីស៊ី រួមមាន៖
- អ្នកជាប់កិច្ចសន្យាទាំងអស់ ឧទាហរណ៍អ្នកពិគ្រោះយោបល់
- តំណាងទីភ្នាក់ងារសមាជិកអាយស៊ីស៊ីទាំងអស់
- ភ្ញៀវ និងអ្នកមកធ្វើទស្សនកិច្ចអាយស៊ីស៊ីទាំងអស់

## ៣. សេចក្តីថ្លែងការណ៍នៃការប្តេជ្ញាចិត្ត

៣.១. អង្គការអាយស៊ីស៊ីប្តេជ្ញា នឹងសម្រេចឱ្យបានពេញលេញ នូវការអនុវត្តគោលការណ៍ទាំង៧ ទាក់ទងនឹងការកេងប្រវ័ញ្ច ការរំលោភបំពាន និងការបៀតបៀនផ្លូវភេទ៖

៣.១.១. ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទដោយបុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ី ជាការប្រព្រឹត្តមិនត្រឹមត្រូវ និងទទួលការចោទប្រកាន់(មានភស្តុតាង) ជាមូលដ្ឋានសម្រាប់ការបញ្ចប់ការងារ ឬកិច្ចសន្យា/កិច្ចព្រមព្រៀង។

៣.១.២. សកម្មភាពផ្លូវភេទជាមួយកុមារ(មនុស្សដែលមានអាយុក្រោម១៨ឆ្នាំ) ត្រូវហាមឃាត់ដោយមិនគិតពីអាយុដែលមានការទទួលស្គាល់ក្នុងតំបន់នោះឡើយ។ ការភាន់ច្រឡំលើអាយុរបស់កុមារ មិនមែនជាលេសការពារខ្លួនទេ។

៣.១.៣. ការដោះដូរប្រាក់ ការងារ កិច្ចសន្យា/កិច្ចព្រមព្រៀង ទំនិញ ឬសេវាកម្មសម្រាប់ការរួមភេទ រួមទាំងការរួមភេទជាថ្នូរនឹងអ្វីមួយ ឬទម្រង់នៃការប្រព្រឹត្តធ្វើឱ្យអាម៉ាស់ ធ្វើឱ្យអាប់ឱន ឬឥរិយាបថកេងប្រវ័ញ្ចដោយបុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ី ត្រូវហាមឃាត់។ នេះរួមបញ្ចូលទាំងការទិញ ការរួមភេទ ឬការដោះដូរជំនួយពីអ្នកចូលរួមគម្រោង។

៣.១.៤. ទំនាក់ទំនងផ្លូវភេទរវាងបុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ី និងអ្នកទទួលផលត្រូវហាមឃាត់។ យោងតាមបរិបទកន្លែងដែលអង្គការអាយស៊ីស៊ីប្រតិបត្តិការ ទំនាក់ទំនងបែបនេះអាចមកពីឥទ្ធិពលអំណាចមិនស្មើគ្នា និងអាចធ្វើឱ្យប៉ះពាល់ដល់ភាពជឿជាក់និងសុចរិតភាពនៃកិច្ចការងាររបស់អង្គការអាយស៊ីស៊ី។ បុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ី ត្រូវតែប្រកាសពីទំនាក់ទំនង ដែលមានស្រាប់មុនៗជាមួយអ្នកទទួលផល ទៅអ្នកគ្រប់គ្រងផ្ទាល់/ប្រធានគម្រោងរបស់ខ្លួន ឬអ្នកចាត់តាំងតំណាងរបស់អង្គការអាយស៊ីស៊ី។

៣.១.៥. នៅពេលបុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ីណាម្នាក់ មានកង្វល់ ឬមានការសង្ស័យលើមិត្តរួមការងារទាក់ទងនឹង **ករបផ** មិនថានៅក្នុងអង្គការអាយស៊ីស៊ី ឬសហគមន៍ គាត់ត្រូវ

តែរាយការណ៍ពីកង្វល់នោះភ្លាមៗ តាមរយៈយន្តការរាយការណ៍ ដែលបានបង្កើតឡើងដូចមានចែងនៅក្នុងគោលនយោបាយនេះ។

៣.១.៦. បុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ី មានកាតព្វកិច្ចបង្កើត និងថែរក្សាបរិយាកាសដែលមានការការពារពី **ករបផ** និងជំរុញការអនុវត្តគោលនយោបាយនេះ។ ប្រធានគម្រោងអាយស៊ីស៊ី មានទំនួលខុសត្រូវក្នុងការគាំទ្រ និងអភិវឌ្ឍប្រព័ន្ធដែលថែរក្សាបរិយាកាសនេះ។

៣.១.៧. បុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ី ត្រូវហាមឃាត់មិនឱ្យយកសេវាកម្មផ្លូវភេទពីអ្នករកស៊ីផ្លូវភេទក្នុងទម្រង់ណាមួយ ខណៈពេលធ្វើដំណើរទៅធ្វើការ(រាប់បញ្ចូលទាំងការធ្វើដំណើរចុះទៅសហគមន៍ និងពេលទំនេរ) ទោះបីជាអាជីវកម្មផ្លូវភេទស្របច្បាប់ នៅក្នុងប្រទេសនោះក៏ដោយ។

៣.២. នាយកប្រតិបត្តិនឹងចាត់តាំងបុគ្គលិកយ៉ាងតិចពីររូប រួមទាំងអ្នកតំណាងមកពីផ្នែកធនធានមនុស្ស ដើម្បីទទួលខុសត្រូវក្នុងការដោះស្រាយបញ្ហាការការពារនៅក្នុងអង្គការ។

៣.៣. អង្គការអាយស៊ីស៊ីជឿជាក់ថា រាល់ទម្រង់នៃ **ករបផ** គឺខុស។ ការរក្សាភាពស្ងៀមស្ងាត់ក៏ខុសដែរ ព្រោះវាស្រដៀងនឹងការចូលរួមជាក់ស្តែងនៃការរំលោភបំពាន ឬការបៀតបៀន ហើយវាធ្វើឱ្យអ្នករំលោភបំពានធ្វើសកម្មភាពរំលោភបំពានដដែលៗ។

## ៤. និយមន័យ

៤.១. **ការការពារ** សកម្មភាព គោលការណ៍ និងនីតិវិធីនានាដែលបង្កើតនិងថែរក្សាបរិយាកាសការពារ ដើម្បីការពារបុគ្គលទាំងឡាយពីការកេងប្រវ័ញ្ច ការរំលោភបំពាន និងគ្រោះថ្នាក់គ្រប់ប្រភេទ។

៤.២. **មនុស្សពេញវ័យងាយរងគ្រោះ** មនុស្សពេញវ័យងាយរងគ្រោះ គឺជាបុគ្គលទាំងឡាយដែលមានអាយុចាប់ពី១៨ឆ្នាំ ដែលអាចត្រូវបានគេដាក់នៅក្នុងស្ថានភាពងាយរងគ្រោះ និងអសមត្ថភាពក្នុងការមើលថែខ្លួនឯង ឬការពារខ្លួនឯងពីគ្រោះថ្នាក់ ឬការកេងប្រវ័ញ្ច។ បុគ្គលម្នាក់ៗអាចងាយរងគ្រោះពី **ករបផ** ដោយសារៈ យេនឌ័រ ពូជសាសន៍ ជាតិសាសន៍ អត្តសញ្ញាណ សាសនា សុខភាពផ្លូវចិត្ត ឬកាយ ពិការភាព ទំនោរផ្លូវភេទ ស្ថានភាពសេដ្ឋកិច្ច ឬសង្គម។

៤.៣. **ការកេងប្រវ័ញ្ចផ្លូវភេទ** រាល់ការរំលោភបំពានជាក់ស្តែង ឬប៉ុនប៉ងស្ថិតក្នុងស្ថានភាពងាយរងគ្រោះ អំណាចខុសគ្នា ឬការជឿទុកចិត្តសម្រាប់គោលបំណងផ្លូវភេទ។ វារួមបញ្ចូលទាំងការកេងចំណេញជាប្រាក់ ផ្នែកសង្គម ឬនយោបាយពីការកេងប្រវ័ញ្ចផ្លូវភេទរបស់អ្នកដទៃ។

៤.៤. **ការរំលោភបំពានផ្លូវភេទ** ការបំពានរាងកាយជាក់ស្តែង ឬគំរាមកំហែងនៃធម្មជាតិផ្លូវភេទ មិនថាដោយកម្លាំងកាយ ឬនៅក្រោមលក្ខខណ្ឌមិនស្មើភាព ឬការបង្ខិតបង្ខំទេ។ វាគ្របដណ្តប់លើបទ

ល្មើសផ្លូវភេទ ដោយមិនកំណត់ត្រឹមតែ ការប៉ុនប៉ងរំលោភសេពសន្ថវៈ(រួមបញ្ចូលការប៉ុនប៉ងបង្ខំឱ្យនរណាម្នាក់រួមភេទតាមមាត់) និងការបំពានផ្លូវភេទ(រួមបញ្ចូលទាំងការថើបនិងការប៉ះពាល់ដោយពុំមានការយល់ព្រម)។ រាល់សកម្មភាពផ្លូវភេទជាមួយកុមារ ត្រូវចាត់ទុកថា ជាការរំលោភបំពានផ្លូវភេទ។

៤.៥. **ការបៀតបៀនផ្លូវភេទ** បុគ្គលម្នាក់បៀតបៀនផ្លូវភេទទៅលើបុគ្គលម្នាក់ ឬច្រើននាក់ ប្រសិនបើបុគ្គលនោះជម្រុញឱ្យមានអារម្មណ៍ផ្លូវភេទដែលមិនពេញចិត្ត ឬសំណើដែលមិនស្វាគមន៍សម្រាប់ការរួមភេទជាថ្នូរនឹងអ្វីមួយ ឬចូលរួមក្នុងឥរិយាបថដែលមិនគាប់ចិត្តផ្សេងទៀតនៃធម្មជាតិផ្លូវភេទដែលធ្វើឱ្យបុគ្គលម្នាក់ ឬច្រើននាក់ មានអារម្មណ៍អាម៉ាស់មុខ ភិតភ័យ ឬអាក់អន់ចិត្ត។ ការបៀតបៀនផ្លូវភេទ អាចមានទម្រង់ផ្សេងៗគ្នា។ វាអាចស្តែងចេញជាក់ស្តែង ឬដោយប្រយោល ដោយកាយវិការឬពាក្យសំដី ធ្វើម្តងហើយម្តងទៀត ឬធ្វើតែមួយដង និងទង្វើមិនគប្បីរបស់បុគ្គលណាម្នាក់(ដែលមានយេនឌ័រណាមួយ) ចំពោះបុគ្គលណាម្នាក់(ដែលមានយេនឌ័រណាមួយ)។ ការបៀតបៀនផ្លូវភេទ អាចត្រូវបានប្រព្រឹត្តទៅលើអ្នកទទួលផល សមាជិកសហគមន៍ ប្រជាពលរដ្ឋទូទៅ ក៏ដូចជាបុគ្គលិក/អ្នកពាក់ព័ន្ធនានាផងដែរ។

## ៥. ពិធីសារអាកប្បកិរិយា

៥.១. អង្គការអាយស៊ីស៊ី រំពឹងថាបុគ្គលិកទាំងអស់៖

៥.១.១. ផ្តល់ការគោរព និងសេចក្តីថ្លៃថ្នូរដល់ប្រជាជនគ្រប់រូបជាមនុស្សជាតិដែលមានទំនាក់ទំនងជាមួយកិច្ចការងាររបស់អង្គការអាយស៊ីស៊ី។

៥.១.២. អាចធ្វើការជាមួយអង្គការអាយស៊ីស៊ី បន្ទាប់ពីពួកគេបានចុះហត្ថលេខាលើគោលនយោបាយ **កករបផ** របស់អង្គការអាយស៊ីស៊ីរួចរាល់។

៥.១.៣. នឹងអនុវត្តតាមក្រមប្រតិបត្តិល្អ។ សូមមើល ឧបសម្ព័ន្ធ១ (ក្រមប្រតិបត្តិល្អរបស់អង្គការអាយស៊ីស៊ី)

៥.១.៤. អ្នកពាក់ព័ន្ធនឹងត្រូវដឹងអំពីគោលនយោបាយ **កករបផ** របស់អង្គការអាយស៊ីស៊ី។ អ្នកពាក់ព័ន្ធនៅតំបន់គោលដៅគម្រោងអាយស៊ីស៊ីនឹងមិនទុកចោលដោយគ្មានការណែនាំ អ្នកពាក់ព័ន្ធនឹងត្រូវចុះហត្ថលេខា និងអនុវត្តតាមគោលការណ៍ណែនាំស្តីពីពិធីសារអាកប្បកិរិយា ដូចជាភ្ញៀវ អ្នកមកធ្វើទស្សនកិច្ច ។ល។ សូមមើល ឧបសម្ព័ន្ធ៤ (គោលការណ៍ណែនាំសម្រាប់អ្នកពាក់ព័ន្ធនៅអង្គការអាយស៊ីស៊ី x២)

៥.២. ប្រសិនបើល្មើសលើពិធីសារអាកប្បកិរិយា នោះនឹងមានចំណាត់ការ ដូចជារាយការណ៍ទៅប៉ូលីស បញ្ឈប់ពីការងារ ដាក់វិន័យ។ល។ ស្របតាមគោលនយោបាយ/នីតិវិធីរបស់អង្គការអាយស៊ីស៊ី និងយោងតាមច្បាប់កម្ពុជា។

## ៦. ការជ្រើសរើស និង សម្រាំងបុគ្គលិក

អង្គការអាយស៊ីស៊ី ប្តេជ្ញាទប់ស្កាត់មិនជួល(ឡើងវិញ) ឬជ្រើសរើស(ឡើងវិញ)ជនល្មើសនៃ **ករបផ** ។ ប្រធានគម្រោង និងថ្នាក់ដឹកនាំ នឹងធានាឱ្យមានដំណើរការជ្រើសរើស និងសម្រាំងបុគ្គលិកយ៉ាងរឹងមាំ ដើម្បីកាត់បន្ថយហានិភ័យនៃការជ្រើសរើសបេក្ខជនដែលជាប់ពាក់ព័ន្ធនឹងហានិភ័យ(មិនអាចទទួលយកបាន)នៃការចូលរួមក្នុងសកម្មភាព **ករបផ** ។

នីតិវិធីរួមមាន៖

- បទសម្ភាសន៍ឥរិយាបថទាក់ទងនឹងការបៀតបៀនផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ អាចត្រូវបានប្រើដើម្បីកំណត់សាវតានៃអាកប្បកិរិយា ជំនឿ ឥរិយាបថ ការជម្រុញទឹកចិត្ត និងគុណតម្លៃរបស់បេក្ខជនចំពោះការងារ ឬការប្រាស្រ័យទាក់ទងជាមួយកុមារ និង/ឬមនុស្សពេញវ័យងាយរងគ្រោះ។
- ការពិនិត្យបញ្ជាក់សេចក្តីសំអាង នឹងត្រូវបានធ្វើឡើងដោយភ្ជាប់ជាមួយសំណួរទាក់ទងនឹងការប្រព្រឹត្តទូទៅរបស់បេក្ខជន និងសំណួរទាក់ទងនឹងការព្រួយបារម្ភអំពីការប្រព្រឹត្តរបស់បេក្ខជន នៅពេលធ្វើការ ឬប្រាស្រ័យទាក់ទងជាមួយកុមារ និង/ឬមនុស្សពេញវ័យងាយរងគ្រោះ នៅក្នុងបរិបទនៃ **ករបផ** ។
- ប្រធានគម្រោងរួមសហការជាមួយអ្នកចាត់តាំងតំណាង នឹងអភិវឌ្ឍកម្មវិធីណែនាំលំអិតដែលគូសបង្ហាញពីអាកប្បកិរិយាដែលរំពឹងទុក និងអាកប្បកិរិយាទាក់ទងនឹងការបៀតបៀនផ្លូវភេទ នៅកន្លែងធ្វើការ ការការពារកុមារ និងការការពារពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារ និងមនុស្សពេញវ័យងាយរងគ្រោះ។
- បុគ្គលិក/អ្នកពាក់ព័ន្ធសក្តានុពលអាយស៊ីស៊ីដែលនឹងធ្វើការដោយផ្ទាល់ និង/ឬមានទំនាក់ទំនងជាប់លាប់ជាទៀងទាត់ជាមួយកុមារ និង/ឬមនុស្សពេញវ័យងាយរងគ្រោះ តម្រូវឱ្យមានការពិនិត្យបញ្ជាក់បន្ថែមតាមរយៈសេចក្តីសំអាងខាងក្រៅ មុនពេលចាប់ផ្តើមការងារ ឬសកម្មភាពណាមួយជាមួយអង្គការអាយស៊ីស៊ី ដូចជាលិខិតបញ្ជាក់កិរិយាមាយាទពីអាជ្ញាធរមូលដ្ឋានជាដើម។

## ៧. ការឆ្លើយតបចំពោះការចោទប្រកាន់

៧.១. បុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ីគ្រប់លំដាប់ថ្នាក់ អាចលើកយកកត្តាសក្តានុពលនៃការកេងប្រវ័ញ្ច ការរំលោភបំពាន និងការបៀតបៀនផ្លូវភេទមកពិភាក្សានៅក្នុងអង្គការ។

៧.២. បុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ីគ្រប់លំដាប់ថ្នាក់ ត្រូវតែរាយការណ៍ពីកង្វល់នានាដែលពួកគេមានចំពោះសុវត្ថិភាព ឬសុខុមាលភាពរបស់មនុស្សពេញវ័យ ទាក់ទងនឹងការកេងប្រវ័ញ្ច ការរំលោភបំពាននិងការបៀតបៀនផ្លូវភេទ។

៧.៣. បុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ីគ្រប់លំដាប់ថ្នាក់ នឹងមិនប្រឈមនឹងការដាក់ទោសទណ្ឌឡើយ ប្រសិនបើពួកគេមានការសង្ស័យ ឬចោទប្រកាន់ទាស់នឹងបុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ីឯទៀត។

៧.៤. នៅពេលមានការចោទប្រកាន់ថាបុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ី បានប្រព្រឹត្តបទល្មើសនោះ អង្គការអាយស៊ីស៊ី នឹងចាត់វិធានការសមស្របណាមួយ ដើម្បីដោះស្រាយស្ថានការណ៍។

៧.៥. ជាបឋម ប្រធានគម្រោងនឹងផ្តល់ព័ត៌មានទៅអ្នកចាត់តាំងតំណាង/នាយកប្រតិបត្តិ។ ប្រសិនបើនាយកប្រតិបត្តិជាកម្មវត្ថុនៃការចោទប្រកាន់ នោះត្រូវផ្តល់ព័ត៌មានទៅប្រធានក្រុមប្រឹក្សាភិបាលវិញ។ បុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ី អាចផ្តល់ព័ត៌មានទៅប្រធានរបស់ខ្លួន ប៉ុន្តែក៏អាចផ្តល់ព័ត៌មានទៅអ្នកចាត់តាំងតំណាង/នាយកប្រតិបត្តិតែម្តងក៏បាន។ សូមមើល ឧបសម្ព័ន្ធ២ (ការឆ្លើយតបចំពោះការចោទប្រកាន់ x២)។

៧.៦. អង្គការអាយស៊ីស៊ី នឹងធ្វើការដោះស្រាយរាល់កង្វល់ដែលបានលើកឡើងយ៉ាងមុតមាំ ហើយធានាថាគ្រប់ភាគីទាំងអស់នឹងត្រូវបានទទួលបានការប្រព្រឹត្តដោយស្មើភាព។

៧.៧. អង្គការអាយស៊ីស៊ី នឹងប្រព្រឹត្តចំពោះជនរងគ្រោះ/អ្នករស់រានមានជីវិតដោយសេចក្តីថ្លៃថ្នូរ និងការគោរព និងធានាផ្តល់អាទិភាពចំពោះតម្រូវការរបស់ពួកគេ ក្នុងសកម្មភាពណាមួយដែលអង្គការចាត់វិធានការ ដើម្បីដោះស្រាយឧប្បត្តិហេតុនេះ។

៧.៨. ការចោទប្រកាន់នេះ នឹងត្រូវរក្សាជាការសម្ងាត់ដោយមានតែអ្នកមានសមត្ថកិច្ចទាក់ទងនឹងការកេងប្រវ័ញ្ច ការរំលោភបំពាន និងការបៀតបៀនផ្លូវភេទប៉ុណ្ណោះ។

៧.៩. បុគ្គលិកអាយស៊ីស៊ីដែលចូលរួមក្នុងដំណើរការចោទប្រកាន់ នឹងត្រូវដឹងអំពីសារៈសំខាន់នៃការរក្សាការសម្ងាត់ ហើយអាចត្រូវបានស្នើសុំឱ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀងរក្សាការសម្ងាត់។

## ៨. ការប្រាស្រ័យទាក់ទង

៨.១. ការប្រាស្រ័យទាក់ទងរបស់អង្គការអាយស៊ីស៊ីជាមួយមនុស្សពេញវ័យ នឹងឆ្លុះបញ្ចាំងពីរូបភាពដែលសមរម្យ និងផ្តល់ការគោរព មិនប្រើប្រាស់ស្ថានភាពរបស់ពួកគេ ដើម្បីធ្វើការកេងប្រវ័ញ្ចឡើយ។

៨.២. អង្គការអាយស៊ីស៊ី នឹងប្រើប្រាស់កុំព្យូទ័រ ទូរស័ព្ទដៃ ម៉ាស៊ីនថតរូបភាពវីដេអូ ឬប្រព័ន្ធសង្គមឱ្យបានត្រឹមត្រូវ និងមិនកេងប្រវ័ញ្ច ឬមិនយាយីរំខានដល់មនុស្សពេញវ័យ ឬមិនចូលឆែកមើលសម្ភារដែលកេងប្រវ័ញ្ចលើមនុស្សពេញវ័យ តាមរយៈប្រព័ន្ធផ្សព្វផ្សាយណាមួយឡើយ។

៨.៣. អង្គការអាយស៊ីស៊ី នឹងមិនដាក់បង្ហាញរូបភាពមនុស្សពេញវ័យនៅក្នុងស្ថានភាពងាយរងគ្រោះឡើយ។

៨.៤. អង្គការអាយស៊ីស៊ី នឹងយកចិត្តទុកដាក់ជាពិសេសក្នុងការការពារអត្តសញ្ញាណរបស់មនុស្សពេញវ័យងាយរងគ្រោះ និងទីតាំងភូមិសាស្ត្រជាក់លាក់របស់ពួកគេ នៅក្នុងឯកសារទំនាក់ទំនងសាធារណៈឡើយ។

៨.៥. ទាក់ទងនឹងការប្រើប្រាស់ព័ត៌មាន និងរូបភាពមើលឃើញ គោលការណ៍របស់អង្គការអាយស៊ីស៊ី គឺផ្តល់ការគោរព និងសេចក្តីថ្លៃថ្នូរ ដោយស្វះស្វែងឱ្យមានការយល់ព្រមមុនពេលថតរូប/វីដេអូ ឬនៅពេលដាក់រូបភាព/វីដេអូ លើគេហទំព័រ ឬសម្ភារបោះពុម្ពផ្សាយ។ សូមមើល ឧបសម្ព័ន្ធ៦ (ទម្រង់ស្នើសុំរូបភាព x២)

## ៩. ការលើកកម្ពស់ការយល់ដឹង និង ការបណ្តុះបណ្តាល

៩.១. អង្គការអាយស៊ីស៊ី មានកាតព្វកិច្ចលើកកម្ពស់ផ្សព្វផ្សាយការយល់ដឹងដល់បុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ីគ្រប់លំដាប់ថ្នាក់ អំពីភាពចាំបាច់នៃការការពារមនុស្សពេញវ័យងាយរងគ្រោះ/កុមារ និងគោលនយោបាយ **កករបផ** ។

៩.១.១. ប្រធានគម្រោង នឹងទទួលខុសត្រូវក្នុងការបណ្តុះបណ្តាលដល់សមាជិកក្រុមបច្ចុប្បន្ន និងថ្មីៗ។

៩.១.២. ថ្នាក់ដឹកនាំអាយស៊ីស៊ី នឹងទទួលខុសត្រូវក្នុងការបណ្តុះបណ្តាល និងពិនិត្យឡើងវិញជាមួយប្រធានគម្រោង។

៩.១.៣. ទាំងប្រធានគម្រោង និងថ្នាក់ដឹកនាំ អាចផ្តល់ការបណ្តុះបណ្តាលស្តីពីគោលនយោបាយ **កករបផ** រួមគ្នាជាមួយនឹងអ្នកចាត់តាំងតំណាង។

៩.២. ការបណ្តុះបណ្តាលដូចមានចែងក្នុងកិច្ចការបណ្តុះបណ្តាល គឺចាំបាច់ត្រូវធ្វើ។

៩.៣. បុគ្គលិកអាយស៊ីស៊ីទាំងអស់ នឹងទទួលបានការបណ្តុះបណ្តាលស្តីពី **កករបផ** ដែលជាផ្នែកមួយនៃការតម្រង់ទិស និងការណែនាំ ការធ្វើឱ្យប្រសើរឡើងវិញ និងការបណ្តុះបណ្តាលការងារជាក់លាក់ដែលតម្រូវ។

៩.៤. ប្រធានគម្រោងម្នាក់ៗ/អ្នកចាត់តាំងតំណាង នឹងធានាថាអ្នកពាក់ព័ន្ធបានយល់និងបានបំពេញតាមលក្ខខ័ណ្ឌនិងផ្តល់ការបណ្តុះបណ្តាលនិងការគាំទ្រចាំបាច់ ដើម្បីឆ្លើយតបនឹងតម្រូវការទាំងនោះ។

៩.៥. បុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ីគ្រប់លំដាប់ថ្នាក់ គួរតែត្រូវបានផ្តល់ឱកាសឱ្យរៀនសូត្រអំពីវិធីការពារមនុស្សពេញវ័យងាយរងគ្រោះ/កុមារ ទទួលស្គាល់ និងឆ្លើយតបចំពោះកង្វល់នានាទាក់ទងនឹង **ករបផ** ។

៩.៦. ព័ត៌មានសមស្របណាមួយដែលមាន ដូចជាទូរស័ព្ទជំនួយបន្ទាន់ និងរបៀបរាយការណ៍ឧបទ្ទវហេតុ និងព័ត៌មានពីសុវត្ថិភាពមនុស្សពេញវ័យងាយរងគ្រោះ/កុមារ នឹងត្រូវបានតាំងបង្ហាញដែលបុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ីគ្រប់លំដាប់ថ្នាក់ អាចចូលយកនិងប្រើប្រាស់បាន។

៩.៧. គោលនយោបាយនេះ នឹងត្រូវដាក់នៅលើគេហទំព័ររបស់អង្គការអាយស៊ីស៊ី។

## ១០. ការអនុវត្តគោលនយោបាយ

- បុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ីគ្រប់លំដាប់ថ្នាក់ នឹងទទួលបាននូវច្បាប់ថតចំលងនៃគោលនយោបាយ **កករបផ** មួយច្បាប់ជាភាសាអង់គ្លេស និង/ឬភាសាខ្មែរ។
- អង្គការអាយស៊ីស៊ី នឹងធ្វើឱ្យប្រាកដថាលេខទូរស័ព្ទត្រូវបានតាំងបង្ហាញឱ្យច្បាស់ៗក្នុងអង្គការ ដើម្បីបង្កភាពងាយស្រួលដល់បុគ្គលគ្រប់គ្នា។ សូមមើល ឧបសម្ព័ន្ធ៥ (ព័ត៌មានទំនាក់ទំនង x២)
- ទម្រង់របាយការណ៍ នឹងរក្សាទុកក្នុងលក្ខណៈដែលបង្កភាពងាយស្រួលដល់បុគ្គលិកទាំងអស់យកបានដើម្បីធ្វើការរាយការណ៍ ក្នុងករណីមានការបំពានលើក្រមដែលបានចែង។ សូមមើល ឧបសម្ព័ន្ធ៣ (ទម្រង់របាយការណ៍ x២)

  ដោយឡែកសម្រាប់មធ្យោបាយជំនួសផ្សេងទៀត ជាពិសេសសម្រាប់អ្នកទទួលផល/សហគមន៍ គឺប្រើប្រាស់"នីតិវិធីដំណើរការបណ្តឹងតវ៉ាសម្រាប់អ្នកទទួលផល" ក្នុងការរាយការណ៍។
- បុគ្គលិកម្នាក់ៗ ត្រូវតែចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ដែលបញ្ជាក់ថា ពួកគេបានអាន និងយល់ព្រមគោរពតាមគោលនយោបាយ និងដឹងថានឹងត្រូវមានចំណាត់ការ ប្រសិនបើមានឥរិយាបថមិនសមរម្យណាមួយកើតឡើង។

## ១១. ការត្រួតពិនិត្យតាមដាន និង វាយតម្លៃ

ថ្នាក់ដឹកនាំ និងប្រធានគម្រោងអាយស៊ីស៊ី ប្តេជ្ញាចិត្តតាមដានឥរិយាបថ និងសកម្មភាពផ្សេងៗរបស់បុគ្គលិក ជាទៀងទាត់និងជាប្រចាំ ដើម្បីធានាការការពារដល់មនុស្សពេញវ័យងាយរងគ្រោះ ឱ្យស្ថិតនៅកម្រិតខ្ពស់បំផុតតាមលទ្ធភាពដែលអាចធ្វើបាន។ ការនេះអាចសម្រេចបានតាមរយៈ៖

- បុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ីគ្រប់លំដាប់ថ្នាក់ យល់ដឹងថាការប្រព្រឹត្តរបស់ពួកគេនឹងត្រូវត្រួតពិនិត្យតាមដាន និងរម្លឹកឡើងវិញយ៉ាងទៀងទាត់ ស្របតាមគោលនយោបាយ **កករបផ** និងនីតិវិធីអាយស៊ីស៊ី។
- រក្សានូវការប្រាស្រ័យទាក់ទងល្អរវាងបុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ីគ្រប់លំដាប់ថ្នាក់ ដើម្បីលើកទឹកចិត្តឱ្យពួកគាត់រាយការណ៍ឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពអំពីរាល់កង្វល់ ឧបទ្ទវហេតុ ឬការប្រព្រឹត្តមិនត្រឹមត្រូវដែលទាក់ទិននឹងការការពារ និងសុវត្ថិភាពមនុស្សពេញវ័យ ឬកុមារពី **ករបផ** ជាពិសេសមនុស្សពេញវ័យដែលងាយរងគ្រោះ។
- ក្នុងករណីឧបទ្ទវហេតុនៃការប្រព្រឹត្តពុំត្រឹមត្រូវ នោះអង្គការអាយស៊ីស៊ីនឹងធ្វើការវាយតម្លៃនិងប៉ាន់ប្រមាណឡើងវិញជាបន្ទាន់ រាល់គ្រប់លំដាប់ថ្នាក់ ដើម្បីធ្វើការកែសម្រួល និងបន្ថែមការការពារតាមភាពចាំបាច់ជាក់ស្តែង។
- អង្គការអាយស៊ីស៊ី នឹងធ្វើឱ្យប្រាកដថាគោលនយោបាយ **កករបផ** ប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពក្នុងគ្រប់កាលៈទេសៈដែលពាក់ព័ន្ធ។ អង្គការអាយស៊ីស៊ី នឹងបន្តត្រួតពិនិត្យតាមដានហានិភ័យទាំងឡាយ(ឧទាហរណ៍ការរៀបចំគម្រោង និងការអនុវត្តគម្រោង) ដែលទាក់ទងនឹងកុមារ និង **ករបផ**

នៃមនុស្សពេញវ័យ រួមទាំងមនុស្សពេញវ័យងាយរងគ្រោះនិងធ្វើការផ្លាស់ប្តូរគោលនយោបាយ **កករបផ** ក្នុងករណីចាំបាច់យ៉ាងហោចណាស់ ៣ឆ្នាំម្តង។

- អភិវឌ្ឍការវាយតម្លៃហានិភ័យសម្រាប់កុមារ/មនុស្សពេញវ័យងាយរងគ្រោះ ចាប់ពីការរៀបចំគម្រោង និងក្នុងកំឡុងពេលអនុវត្តការការងាររបស់អង្គការអាយស៊ីស៊ី។ សូមមើល ឧបសម្ព័ន្ធ៧ (គំរូវាយតម្លៃហានិភ័យ)

## ១២. សេចក្តីថ្លែងការណ៍ពីការប្តេជ្ញាចិត្ត

បុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ីគ្រប់លំដាប់ថ្នាក់ដែលមានទំនាក់ទំនងនឹងការងាររបស់អង្គការអាយស៊ីស៊ី ត្រូវចុះហត្ថលេខា និងអះអាងបញ្ជាក់ថា ពួកគាត់បានអាន និងបានយល់ពីគោលនយោបាយ **កករបផ** ហើយយល់ព្រមអនុវត្តតាមគោលនយោបាយ **កករបផ** របស់អង្គការអាយស៊ីស៊ី។

ច្បាប់ចម្លង១ច្បាប់ នឹងត្រូវរក្សាទុកនៅការិយាល័យកណ្តាល ឬនៅការិយាល័យគម្រោងរបស់អង្គការអាយស៊ីស៊ី។ បុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ី នឹងចុះហត្ថលេខាលើកិច្ចសន្យាការងារ និងត្រូវយល់ព្រមអនុវត្តតាមគោលនយោបាយ **កករបផ** របស់អង្គការអាយស៊ីស៊ី។

**ខ្ញុំបាទ/នាងខ្ញុំឈ្មោះ______________________________សូមបញ្ជាក់អះអាងថា៖**

១. ខ្ញុំបានអាន បានយល់ និងអនុវត្តតាមគោលនយាបាយ **កករបផ** របស់អង្គការអាយស៊ីស៊ី

២. ខ្ញុំនឹងធ្វើតាមនិតិវិធីដែលបានចែងក្នុងគោលនយាបាយគោលនយោបាយ **កករបផ** របស់អង្គការអាយស៊ីស៊ី។

៣. ខ្ញុំមិនធ្លាប់ជាប់ទោសទណ្ឌបទល្មើសផ្សេងៗទាក់ទងនឹង **ករបផ** ឡើយ។

៤. ខ្ញុំយល់ដឹងថា ប្រសិនបើមានបណ្តឹងទាស់នឹងខ្ញុំទាក់ទិននឹង **ករបផ** លើមនុស្សពេញវ័យ ឬកុមារ ក្នុងខណៈពេលដែលខ្ញុំចូលរួមជាមួយសកម្មភាពរបស់អង្គការអាយស៊ីស៊ី នោះការចោទប្រកាន់នឹងត្រូវបានធ្វើការស៊ើបអង្កេតយ៉ាងហ្មត់ចត់ ក្នុងកិច្ចសហប្រតិបត្តិការជាមួយនឹងអាជ្ញាធរសមត្ថកិច្ចមានជំនាញ។

ហត្ថលេខា___________________________ កាលបរិច្ឆេទ______________________

## សទ្ទានុក្រមពាក្យបច្ចេកទេស

**ការសម្ងាត់** សំដៅដល់ការការពារព័ត៌មានផ្ទាល់ខ្លួន អង្គការអោយស៊ីស៊ីនឹងព្យាយាមរក្សាការសម្ងាត់ នៅពេលដោះស្រាយកង្វល់ បញ្ហានិងករណីគួរឱ្យសង្ស័យ លើកលែងតែជននោះមានគ្រោះថ្នាក់ដល់ខ្លួនឯង ឬអ្នកដទៃ។

**បណ្តឹងតវ៉ា** សេចក្តីថ្លែងការណ៍ពីអ្វីមួយខុស ឬមិនពេញចិត្ត។

**អ្នកចាត់តាំងតំណាង** គណៈកម្មាធិការ(បន្ថែមអ្នកតំណាងមកពីផ្នែកធនធានមនុស្ស) តែងតាំងដោយនាយកប្រតិបត្តិ ហើយមានការទទួលខុសត្រូវក្នុងការដោះស្រាយបញ្ហាកិច្ចការពារនានានៅក្នុងអង្គការ។